ការបោះផ្សាយដោយមានការពិនិត្យកែសំរួលឆ្នាំ 2005

# គោលការណ៍ណែនាំស្ដីអំពីការសិក្សារៀនសូត្រតាមការដ្ឋានសំរាប់មាតាបិតានិងអ្នកថែទាំ

សំរាប់សិស្សដែលសិក្សានៅតាមសាលារដ្ឋ NSW និងសិស្សដែលចូលរៀនវគ្គសិក្សា HSC នៅវិជ្ជាស្ថាន TAFE NSW



គោលការណ៍ណែនាំនេះ បង្ហាញនូវទស្សនៈពាក់ព័ន្ធនឹងការរៀនសូត្រនៅការដ្ឋាន កិច្ចការពាក់ព័ន្ធទាំងឡាយ និងជំនួយដែលមានជូនមាតាបិតា អ្នកថែទាំ និងសិស្ស។

NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING

KHMER - Parents and Carers Guide to Workplace Learning

# ផ្នែក 1

## អំពីការរៀនសូត្រនៅតាមការដ្ឋាន

- កម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋាន គឺជាផ្នែកមួយនៃកម្មវិធីសិក្សាក៏រិតមធ្យមសិក្សានៅរដ្ឋ NSW ។ កម្មវិធីទាំងនេះជំរុញឲ្យសិស្សចំណាយពេល ដោយមានផែនការរៀបចំ មួយរយៈកាល តាមធម្មតាគឺរយៈពេលមួយអាទិត្យ នៅតាមការដ្ឋានណាមួយ ដែលសិស្សជ្រើសរើស ដើម្បីជាការពង្រឹងដ៏ថ្លៃថ្លា ដល់ការសិក្សារៀនសូត្រនៅក្នុងថ្នាក់របស់សិស្ស។
- ការសិក្សារៀនសូត្រនៅតាមការដ្ឋានគឺជាសកម្មភាពសមរម្យចំពោះសិស្សទាំងអស់នៅក្នុងសាលារៀនរដ្ឋ NSW និងគ្រប់ជាន់ថ្នាក់នៃសមត្ថភាព។

## ហេតុអ្វីបានជាការសិក្សារៀនសូត្រនៅតាមការដ្ឋានមានសារសំខាន់?

ការសិក្សារៀនសូត្រអំពីការដ្ឋានជួយឲ្យសិស្ស៖

- ក្រេបយកចំណេះដោយផ្ទាល់ស្ដីអំពីភាពផ្លាស់ប្ដូរមិនឈប់ឈរនៃពិភពការងារ និងសហគ្រាស
- សាកល្បងការងារនិងសេចក្ដីប្រាថ្នារបស់ខ្លួនពាក់ព័ន្ធនឹងអាជីព
- បំពេញវគ្គការងារនៅក្នុងមជ្ឈដ្ឋានឧស្សាហកម្មណាមួយដែលសមស្រប
- ដកស្រង់យកបទពិសោធន៍ដោយផ្ទាល់នូវលក្ខណៈសម្បត្តិដែលនិយោជកស្វែងចង់បាន
- ក្រេបយកជំនាញការងារទូទៅមានដូចជាទំនាក់ទំនងតាមការដ្ឋាន "ជំនាញការ ប្រស្រ័យទាក់ទងរវាងមនុស្ស និង មនុស្ស" និង/ឬជំនាញការឧស្សាហកម្ម ពិសេស មានដូចជាសមត្ថភាពប៉ិនប្រសប់ក្នុងការរៀនវគ្គអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (VET)
- មានការជឿជាក់និងភាពចាស់ទុំកាន់តែខ្លាំងឡើង ក៏ដូចជាយល់ដឹងអំពីខ្លួនឯងកាន់តែច្រើនឡើង តាមរយៈការចូលរួមនៅក្នុងមជ្ឈដ្ឋានការងារដ៏មមាញឹក របស់មនុស្សពេញវ័យ
- ស្វែងយល់អំពីទំនាក់ទំនងរវាងការសិក្សានៅតាមសាលារៀន ការហ្វឹកហ្វឺននៅ តាមវិជ្ជាស្ថាន TAFE NSW ឬនៅតាមអង្គការហ្វឹកហ្វឺនក្នុងសហគមន៍ឬក៏ឯកជន ដែលមានការចុះឈ្មោះត្រឹមត្រូវ (private or community registered training organisation [P/C RTO] ) ការសិក្សានៅតាមសកលវិទ្យាល័យ ព្រមទាំងការហ្វឹកហ្វឺនបណ្ដុះបណ្ដាល និងការងារទៅពេលអនាគត
- ចាត់ចែងដោះស្រាយការធ្វើដំណើររបស់ខ្លួនឆ្លងកាត់ក៏រិតមធ្យមសិក្សា ទៅបន្តការសិក្សាអប់រំថែមទៀត ការហ្វឹកហ្វឺនបណ្ដុះបណ្ដាលនិងការងារ។

## តើប្រភេទធំៗពីរនៃកម្មវិធីសិក្សារៀនសូត្រនៅការដ្ឋានមានអ្វីខ្លះ?

### Work Experience

- សិស្សចូលរួមនៅក្នុងការណែនាំបង្ហាត់បង្រៀនទូទៅស្ដីអំពី "ពិភពការងារ" ជាធម្មតា នៅក្នុងវិស័យណាមួយដែលសិស្សជ្រើសរើស។ សិស្សអាចសង្កេតមើលការងារផ្សេងៗគ្នា ហើយធ្វើការងារណាដែលសមរម្យនឹងក៏រិតនៃជំនាញការរបស់ខ្លួន ដោយមានការត្រួតពិនិត្យ។
- Work experienceពង្រឹងដល់កម្មវិធីអប់រំការងារ មុខអាជីព និងសហគ្រាស ក៏ដូចគ្នាទៅនឹងការងារវគ្គសិក្សាដទៃទៀតនិងសកម្មភាពផែនការមុខអាជីពរបស់សាលារៀន។
- កម្មវិធីទាំងនេះ តាមធម្មតាសិក្សាដោយសិស្សថ្នាក់ទី 9 និងថ្នាក់ទី 10 ។ សិស្សអាចមានឱកាសថែមទៀត នៅថ្នាក់ទី 11 និងថ្នាក់ទី 12 ។

### Work Placement

- Work placement ពាក់ព័ន្ធនឹងសិស្សនៅថ្នាក់ទី 11 និងទី 12 ដែលកំពុងតែរៀនវគ្គសិក្សាឧស្សាហកម្មណាមួយដែលមានការទទួលស្គាល់ ជាផ្នែកមួយនៃ វិញ្ញាបនបត្រ ក៏រិតមធ្យមសិក្សារបស់សិស្ស (Higher School Certificate [HSC]) ។ វគ្គសិក្សាទាំងនេះ រួមមានសេវាកម្មអាជីវកម្ម សំណង់ គ្រឿងកំសាន្ដ បដិសណ្ឋារកិច្ច ព័ត៌មានវិទ្យា លោហធាតុនិងវិស្វកម្ម ឧស្សាហកម្មធនធានដើម ការលក់រាយនិងទេសចរណ៍។
- វគ្គសិក្សាវិជ្ជាជីវៈទាំងនេះ អាចបង្ហាត់ដោយសាលារៀន ឬដោយវិជ្ជាស្ថាន TAFE NSW ណាមួយ, ឬជួនកាលធ្វើឡើងដោយអង្គការហ្វឹកហ្វឺនក្នុងសហគមន៍ ឬក៏ឯកជនដែលមានការចុះឈ្មោះត្រឹមត្រូវ (private or community registered training organisation [P/C RTO]) ដែលគេស្គាល់ផងដែរថាជា "ស្ថាប័នឯកជន" ដែលជួលដោយសាលារៀនដើម្បីបង្រៀនដល់សិស្សនូវវគ្គសិក្សាផ្ដោតទៅលើឧស្សាហម្មពិសសេសណាមួយ។
- Work placement គឺជា**តម្រូវការចាំបាច់**របស់ HSC សំរាប់វគ្គសិក្សាទាំងឡាយ ដែលមានរាយឈ្មោះនៅលើបញ្ជីខាងលើនេះ។ នៅក្នុងអំឡុងពេល work placement និយោជកដែលទទួលយកសិស្ស មើលការខុសត្រូវលើសិស្ស នៅក្នុងខណៈដែលសិស្សចូលរួមជានិយោជិតស្ម័គ្រចិត្តម្នាក់នៅក្នុងការដ្ឋាន របស់និយោជកនោះ ដោយការអនុវត្ត និងពង្រីកជំនាញការឧស្សាហកម្មជាក់លាក់ដែលសិស្សបានរៀនសូត្រពីការងារហ្វឹកហាត់ធ្វើនៅឯសាលារៀន, TAFE NSW ឬនៅឯ P/C RTO ។
- គ្រូប្រើ Work placement ដើម្បីប្រមូលភស្ដុតាងអំពីសមិទ្ធផលរបស់សិស្សពាក់ព័ន្ធនឹងសមត្ថភាពតាមក៏រិតស្ដង់ដារឧស្សាហកម្ម។ កិច្ចការនេះអាចប្រព្រឹត្តទៅ ដោយការរួមកម្លាំងជាដៃគូជាមួយនឹងអ្នកដែលមានសញ្ញាប័ត្រសមរម្យខាងផ្នែកវាយតម្លៃលើការដ្ឋាន។
- ជំនាញការនិងការប៉ិនប្រសប់របស់សិស្សអាចញ៉ាំងឲ្យមានការទទួលសញ្ញាប័ត្រ VET ពាក់ព័ន្ធនឹងឧស្សាហកម្មជាក់លាក់ណាមួយ ដែលមានការទទួលស្គាល់ពាសពេញប្រទេសអូស្ត្រាលី ។

## តើមានកម្មវិធីសិក្សារៀនសូត្រតាមការដ្ឋានដទៃទៀតឬទេ?

- ប្រាកដជាមាន។ កម្មវិធីទាំងនេះរួមមានកម្មវិធីអប់រំឲ្យយល់ដឹងពីសហគ្រាស ការរៀនសូត្រអំពីសហគមន៍ និងកម្មវិធីប្រៀនប្រដៅសិស្ស បង្ហាត់ដោយនិយោជកនៅតាមការដ្ឋាន។

បើសិនជាលោកអ្នកមានបញ្ហាមិនយល់អំពីឯកសារនេះ ឬក៏ចង់បានព័ត៌មានបន្ថែម សូមទូរស័ព្ទទៅសេវាបកប្រែភាសាលេខ 131 450, ដើម្បីស្នើសុំអ្នកបកប្រែភាសាម្នាក់ដែលនិយាយជាភាសាលោកអ្នក ហើយសុំឲ្យគេទូរស័ព្ទទៅសាលារៀន ឬក៏បើចាំបាច់ គឺវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO ឲ្យលោកអ្នក។ សេវាបកប្រែភាសានេះនឹងផ្តល់ជូនលោកអ្នកដោយគិតថ្លៃឡើយ។

## ផ្នែក 2
## របៀបដែលការសិក្សារៀនសូត្រនៅតាមការដ្ឋានដំណើរការ

- កម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋានមានការទទួលស្គាល់និងយល់ព្រមដោយសាលារៀន ហើយជួនកាលនោះ ដោយ TAFE NSW ឬ P/C RTO ណាមួយដែលគេជួលឲ្យបង្ហាត់។
- សិស្សភាគច្រើននឹងមានឱកាសដើម្បីចូលរួមនៅក្នុងការសិក្សារៀនសូត្រនៅក្នុងដំណាក់កាលណាមួយ នៅក្នុងអំឡុងពេលរៀននៅសាលាមធ្យមសិក្សា។
- ការដាក់សិស្សឲ្យឯកបទពិសោធន៍ការងារតាមការដ្ឋាន គឺធ្វើឡើងដោយផ្អែកទៅលើកិច្ចការវគ្គសិក្សា ផែនការមុខអាជីព និងការសិក្សាដទៃទៀតរបស់សិស្ស។
- សិស្សចូលរួមនៅក្នុងសកម្មភាពទាំងឡាយរៀបចំឡើងដោយគ្រូមុននឹងមានការដាក់សិស្សឲ្យឯកបទពិសោធន៍ការងារតាមការដ្ឋាន ដើម្បីឲ្យសិស្សអាចត្រៀមលក្ខណៈបានល្អប្រសើរសំរាប់បទពិសោធន៍នេះ។
- និយោជកដែលទទួលសិស្ស ឬអ្នកដែលគេជ្រើសតាំងឲ្យមើលការខុសត្រូវ នឹងមើលការខុសត្រូវលើសិស្ស នៅតាមការដ្ឋាន។ មុខការរបស់គេគឺត្រូវធ្វើឲ្យប្រាកដថាសិស្សមានសកម្មភាពសមរម្យ ដើម្បីជំរុញទឹកចិត្តនិងធ្វើឲ្យគេប្រឹងប្រែងព្យាយាម។
- សាលារៀន, វិជ្ជាស្ថាន TAFE NSW ឬ P/C RTO របស់លោកអ្នក ក៏មានភារកិច្ចមួយផងដែរក្នុងការថែគ្រងសិស្សនៅតាមការដ្ឋាន។ គ្រូម្នាក់នឹងធ្វើដំណើរដើម្បីពិនិត្យមើលការខុសត្រូវ ឬក៏ទូរស័ព្ទទៅកាន់និយោជកដែលទទួលសិស្ស ឬក៏អ្នកមើលការខុសត្រូវនៅការដ្ឋាន និងសិស្សផងដែរ ដើម្បីឆែកអំពីការរីកចំរើននិងសុខុមាលភាពរបស់សិស្ស។ ការពិភាក្សាជាមួយសិស្សក្រោយពីការដាក់សិស្សឲ្យឯកបទពិសោធន៍ការងារតាមការដ្ឋាន ដើម្បីស្វែងយល់ការរីកចំរើនក៏ត្រូវតែប្រព្រឹត្តទៅផងដែរ។

### តើសិស្សទទួលការងារនោះដោយរបៀបណា?

ខាងក្រោមនេះគឺជាវិធីខ្លះដែលដែលគេផ្គូផ្គងសិស្សទៅនឹងការងារទាំងនោះ។

- សាលារៀន ឬក៏ជួនកាលនោះវិជ្ជាស្ថាន TAFE NSW ឬ P/C RTO រកការងារនៅតាមការដ្ឋានទាំងនោះ ហើយបន្ទាប់មកគេឲ្យការងារទាំងនោះទៅសិស្សដោយផ្អែកទៅតាមតម្រូវការរបស់និយោជក និងចំណង់ចំណូលចិត្ត, សេចក្តីត្រូវការ និងផែនការមុខអាជីពរបស់សិស្ស។
- HSC VET **work placements** សំខាន់ចាំបាច់ គឺធ្វើឡើងតាមរយៈគំរោងភាពជាដៃគូសហគមន៍មូលដ្ឋាន (Local Community Partnerships [LCPs]) បង្កើតឡើងដើម្បីសំរបសំរួលការដាក់សិស្សឲ្យឯកបទពិសោធន៍ការងារតាមការដ្ឋានទាំងនេះ។ គ្រូផ្គូផ្គងសិស្សជាមួយនឹងការងារតាមការដ្ឋានដែលមានគុណភាពផ្តល់ដោយ LCP ។
- សិស្សស្វែងរកដោយខ្លួនឯងនូវកន្លែង **work experience** ដោយមានជំនួយពីសាលារៀន និងមាតាបិតាឬអ្នកថែទាំរបស់ខ្លួន ហើយដាក់បញ្ជូនកន្លែងនោះ ទៅសាលារៀន ឬក៏វិជ្ជាស្ថាន TAFE NSW ដើម្បីសុំការយល់ព្រម។ នៅក្នុងស្ថានភាពដែលសិស្សរកបានដោយខ្លួនឯងនូវកន្លែងជាមួយនឹងនិយោជកដែលទទួលយកសិស្សនោះ សាលារៀន ឬវិជ្ជាស្ថាន TAFE NSW នឹងផ្តល់ឲ្យសិស្សនូវគោលការណ៍ណែនាំ និងលិខិតឧទ្ទេសនាមសំរាប់និយោជក។

### តើនៅក្នុងដំណាក់កាលណាដែលសិស្សអាចចូលរួមបាននោះ?

សិស្សទាំងឡាយណាដែលមានអាយុ 14 ឆ្នាំនិងលើសពី 14 ឆ្នាំគឺសុទ្ធតែអាចចូលរួមបានហើយ។ យ៉ាងណាមិញ មានការដាក់កំហិតមួយចំនួនទៅលើពេលវេលា ដែលសិស្សអាចចូលរួម បើសិនជាសិស្សនោះមានអាយុក្រោម 15 ឆ្នាំ។

### តើនៅពេលណាដែលសិស្សធ្វើការសិក្សារៀនសូត្រការងារតាមការដ្ឋាន?

- សាលារៀន, វិជ្ជាស្ថាន TAFE NSW ឬ P/C RTO ធ្វើការសំរេចនូវពេលវេលា នៅក្នុងអំឡុងឆ្នាំដែលគេត្រូវរៀបចំឲ្យមានសកម្មភាពសិក្សារៀនសូត្រការងារតាមការដ្ឋាន និងថាតើសិស្សណាខ្លះដែលត្រូវចូលរួម ដោយតាមធម្មតា មានការប្រឹក្សាយោបល់ជាមួយសហគមន៍របស់គេ។ សាលារៀននឹងផ្តល់ព័ត៌មានពិស្តារអំពីកម្មវិធីនីមួយៗទៅមាតាបិតា ឬអ្នកថែទាំ។
- មានការរំពឹងទុកថា សិស្សត្រូវតែទៅកាន់ការដ្ឋានជារៀងរាល់ថ្ងៃនៃកម្មវិធីនេះ។
- ដោយសារការឯកពិសោធន៍ការងារតាមការដ្ឋានគឺជាផ្នែកមួយនៃកម្មវិធីសិក្សានេះ កម្មវិធីទាំងឡាយជាទូទៅធ្វើប្រតិបត្តិការតែនៅក្នុងអំឡុងត្រីមាសដែលសាលារៀន ឬ TAFE NSW ធ្វើការប៉ុណ្ណោះ។
- កម្មវិធីសិក្សារៀនសូត្រការងារតាមការដ្ឋាន សំរាប់សិស្សថ្នាក់ទី 9 និងថ្នាក់ទី 10 អាចដំណើរការតែនៅក្នុងត្រីមាសសាលារៀនបើកដំណើរការប៉ុណ្ណោះ។
- សិស្សមានអាយុក្រោម 15 ឆ្នាំមិនអាចធ្វើការមុនម៉ោង 7 ព្រឹក ឬក្រោយម៉ោង 6 ល្ងាចបានឡើយ។
- នៅក្នុងកាលៈទេសៈលើកលែងចេញ នាយកសាលា (Principal) អាចផ្តល់ការយល់ព្រមដល់ការសិក្សារៀនសូត្រការងារតាមការដ្ឋាន សំរាប់សិស្សរៀងៗខ្លួនដែលរៀននៅថ្នាក់ទី 11 និងថ្នាក់ទី 12 នៅក្នុងអំឡុងពេលសាលាវិស្សមកាល។ សកម្មភាពនេះមិនរួមបញ្ចូលវិស្សមកាលបុណ្យណូអែលឡើយ។
- ការសិក្សារៀនសូត្រការងារតាមការដ្ឋាន អាចបន្តចូលទៅចុងសប្តាហ៍បាន ដោយមានការយល់ព្រមពិសេសពីនាយកសាលា ប៉ុន្តែធ្វើទៅបានតែនៅក្នុងល្បឹកណាដែលការងារនៅចុងសប្តាហ៍ជាតម្រូវការចាំបាច់ របស់ឧស្សាហកម្មប៉ុណ្ណោះ។

## តើសិស្សត្រូវធ្វើដំណើរចម្ងាយឆ្ងាយប៉ុណ្ណា?

- កន្លែងឯកពិសោធន៍ការងារតាមការដ្ឋានភាគច្រើន នឹងឋិតនៅក្នុងរង្វង់នៃចម្ងាយដែលអាចធ្វើដំណើរពីផ្ទះបាន។
- សិស្សអាចទទួលនូវការយល់ព្រមពិសេសមួយសំរាប់ការឯកពិសោធន៍ការងារតាមការដ្ឋាន ដែលតម្រូវឲ្យមានការស្នាក់នៅឆ្ងាយពីផ្ទះ។ ការយល់ព្រមពិសេសនេះ គឺអាស្រ័យទៅលើភស្តុតាងដែលបង្ហាញថា គុណប្រយោជន៍នៃការសិក្សាសំរាប់សិស្សគឺជាការគាប់ប្រសើរក្រៃលែង។ ការយល់ព្រមពិសេសនេះ ក៏អាស្រ័យទៅលើការរៀបចំឲ្យបានជាទីពេញចិត្តសំរាប់ការពិនិត្យមើលការខុសត្រូវតាមការដ្ឋាន យានយន្តធ្វើដំណើរ ទីស្នាក់អាស្រ័យ និងការពិនិត្យមើលការខុសត្រូវនៅពេលយប់ផងដែរ។
- ការផ្តល់ការយល់ព្រមឲ្យសិស្សទៅឯកពិសោធន៍ការងារតាមការដ្ឋាននៅតាមរដ្ឋផ្សេងទៀតគឺជារឿងដ៏កំរ លើកលែងតែសាលារៀននោះឋិតនៅក្បែរ ឬជាប់ព្រំប្រទល់ ឬក៏ឧស្សាហកម្មនោះពុំមាននៅក្នុងរដ្ឋ NSW ។ បើសិនជាលោកអ្នកធ្វើការគិតគូរអំពីការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាន នៅតាមរដ្ឋដទៃទៀតនោះ លោកអ្នកគប្បីទាក់ទងសាលាឬក៏វិជ្ជាស្ថាន TAFE NSW ដែលមានការពាក់ព័ន្ធក្នុងរឿងនេះ។

## ចុះការធ្វើដំណើរវិញ មានការរៀបចំយ៉ាងណាដែរ?

- មាតាបិតា និងអ្នកថែទាំត្រូវជួយសិស្សរៀបចំការធ្វើដំណើររបស់ខ្លួនដោយប្រុងប្រយ័ត្ន។ សាលារៀន, វិជ្ជាស្ថាន TAFE NSW ឬ P/C RTO ក៏ត្រូវតែជួយ សិស្សផងដែរ ក្នុងការរៀបចំផែនការធ្វើដំណើរ។
- សូមទូរស័ព្ទទៅ **Transport InfoLine** លេខ 131 500 ឬក៏ឆែកមើលវិបសាយ **www.131500.com** ដើម្បីមើលតារាងពេលវេលានិងព័ត៌មានដទៃទៀត ពាក់ព័ន្ធនឹងការធ្វើដំណើរតាមយានយន្តសាធារណៈ។
- ក្នុងនាមជាមាតាបិតា ឬអ្នកថែទាំ លោកអ្នកត្រូវតែមានការកក់ក្តៅចិត្តថា កូនលោកអ្នកអាចគ្រប់គ្រងការរៀបចំការធ្វើដំណើរនេះបានដោយសុវត្ថិភាព។ បើសិនជាលោកអ្នកមានការបារម្ភអ្វីមួយ លោកអ្នកគប្បីពិភាក្សាបញ្ហាទាំងនេះ ជាមួយនឹង អ្នករៀបចំកម្មវិធីនេះដោយផ្ទាល់តែម្តង។
- សិស្សត្រូវចំណាយលើការធ្វើដំណើរទាំងអស់។ សាលារំពឹងទុកថា មាតាបិតា ឬអ្នកថែទាំនឹងឧបត្ថម្ភជួយសិស្ស នៅក្នុងអំឡុងពេលនៃកម្មវិធីសិក្សារៀនសូត្រការងារតាមការដ្ឋាននេះ។
- ការធ្វើដំណើរតាមយានយន្តសាធារណៈ មានដូចជារថភ្លើង រថយន្តក្រុង និង កាណូតជាដើម នឹងមានបញ្ចុះតម្លៃជូនសិស្ស។ ការបញ្ចុះតម្លៃនេះក៏អាចមាន នៅតាមរថយន្តក្រុងឯកជនផងដែរ។
- បើសិនជាត្រូវការ សាលារៀនលោកអ្នកអាចរៀបចំឲ្យមាន ប័ណ្ណ អត្តសញ្ញាណ ឬក៏ភស្តុតាងអំពីអាយុ សំរាប់ផ្តល់ឲ្យសិស្ស ទៅតាមសំណូមពរ។

## តើការយល់ព្រមអ្វីខ្លះដែលគេត្រូវការចាំបាច់?

- សាលារៀន ឬក៏វិជ្ជាស្ថាន TAFE NSW ឬ P/C RTO នឹងស្វែងសុំការអនុញ្ញាត ពីលោកអ្នក ដើម្បីឲ្យសិស្សបំពេញកិច្ចការសិក្សារៀនសូត្រការងារតាមការដ្ឋាន នីមួយៗទៅតាមសំណើ។
- ត្រូវមានការកត់ត្រាទុកជាប្រូវហៃ នៅក្នុងកំណត់ត្រាឯកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស (Student Placement Record) អំពីសកម្មភាពនីមួយៗ នៃការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាន។
- កំណត់ត្រាឯកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស ត្រូវមានការចុះហត្ថលេខាពីសិស្ស និយោជកដែលទទួលសិស្ស និងរូបលោកអ្នក មុននឹង សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO ផ្តល់ការយល់ព្រមចុងក្រោយ។ នៅគ្រាដែលការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋានបាន ទទួលការយល់ព្រមហើយនោះ លោកអ្នកនឹងបានទទួលសំណៅមួយច្បាប់នៃកំណត់ត្រាឯកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស។ សូមរក្សាទុកសំណុំរឿងនេះសំរាប់តម្រូវការទៅថ្ងៃមុខទៀត។
- ជួនកាល គេមិនអាចរកនិយោជកឬពេលវេលាតាមសំណូមពរឬក៏ការចង់បានរបស់លោកអ្នក សំរាប់ឲ្យកូនលោកអ្នកទៅបំពេញកិច្ចការឯកពិសោធន៍ការងារ តាមការដ្ឋាននោះបានឡើយ។ លោកអ្នកនឹងត្រូវតែធ្វើការពិភាក្សារឿងនេះជាមួយសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ។
- សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO ត្រូវមានការពេញចិត្តថា សំណើដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាននេះផ្តល់នូវសុវត្ថិភាព និងបទពិសោធន៍សមរម្យសំរាប់សិស្ស ព្រមទាំងផ្តល់លទ្ធភាពឲ្យគេអាចរក្សាការថែគ្រងសិស្សនោះបានទៀតផង។
- និយោជកទទួលយកសិស្សត្រូវតែបង្ហាញនៅក្នុងកំណត់ត្រាឯកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស អំពីរបៀបដែលគេរក្សាការថែគ្រងសុវត្ថិភាពសិស្សបាន នៅក្នុងអំឡុងពេលសិស្សឯកពិសោធន៍ការងារតាមការដ្ឋាននេះ។
- សិស្សនឹងត្រូវបំពេញវគ្គហ្វឹកហ្វឺនផ្នែកសុវត្ថិភាពនិងសុខភាពផ្នែកការងារ (occupational health and safety training) ជាក់លាក់ជាមុនសិន មុននឹងទទួលយកសំណើឯកបទពិសោធន៍ការងារតាមការដ្ឋាន ដ្បិតនេះជាលក្ខខណ្ឌមួយសំរាប់ការយល់ព្រម ដល់សំណើដាក់សិស្សឲ្យឯកពិសោធន៍ ការងារតាមការដ្ឋានរបស់វគ្គសិក្សា HSC VET និងការសិក្សារៀនសូត្រអំពីការដ្ឋានណាមួយ នៅក្នុងឧស្សាហកម្មសំណង់ ។ ចំពោះព័ត៌មានបន្ថែម សូមទាក់ទងសាលារៀន ឬក៏វិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO ។

## តើកូនខ្ញុំនឹងទទួលប្រាក់បៀវត្សរ៍ឬទេ?

- អត់ទេ។ គេចាត់ទុកសិស្សជា "បុគ្គលិកស្ម័គ្រចិត្ត" ហេតុដូច្នេះសិស្សនឹងមិនបានទទួលបៀវត្សរ៍ឡើយ។ នៅក្រោមច្បាប់វិស្សមកាលប្រចាំឆ្នាំរដ្ឋញូវសោវ៉ែល (NSW Annual Holidays Act) និង ច្បាប់សងជំងឺចិត្តដល់និយោជិត (Workers' Compensation Act) និយោជកដែលទទួលយកសិស្សមិនចាំបាច់ផ្តល់ប្រាក់បៀវត្សរ៍អ្វីទៅសិស្សឡើយ នៅក្រោមបទបញ្ញត្តិរដ្ឋ ឬសហព័ន្ធដែលតម្រូវឲ្យអនុវត្តនៅក្នុងឧស្សាហកម្មជាក់លាក់។

- Department of Education and Training ផ្តល់ការធានារ៉ាប់រងដល់សិស្ស ដែលឋិតនៅក្នុងកម្មវិធីសិក្សារៀនសូត្រអំពីការដ្ឋាន។ យ៉ាងណាមិញ ការធានានេះ គ្មានសុពលភាព សំរាប់សិស្សដែលទទួលយកបៀវត្សរ៍សំរាប់កម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋានឡើយ។
- មានការលើកលែងមួយ គឺនៅក្នុងខណៈដែលកូនរបស់លោកអ្នកមានការងារ មិនពេញពេលមួយធ្វើ ហើយកូនរបស់លោកអ្នក ប្រើការងារនេះសំរាប់បំពេញតម្រូវការចាំបាច់នៃវគ្គសិក្សា HSC VET ក្នុងការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាន។

  - ការរៀបចំបែបនេះ ត្រូវមានការចរចាជាមួយនឹងនិយោជក ហើយនិងយល់ព្រមដោយសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO ។
  - នៅក្នុងករណីនេះ សិស្សមិនមែនជាបុគ្គលិកស្ម័គ្រចិត្តឡើយ ហើយការរៀបចំឲ្យមានការធានារ៉ាប់រងត្រូវតែធ្វើឡើងចំពោះសិស្សដោយនិយោជក។

## ចុះអាជ្ញាប័ណ្ណនិងការអនុញ្ញាតនានានោះយ៉ាងម៉េចដែរ?

- សិស្សមិនគួរធ្វើការងារណាមួយដែលតម្រូវឲ្យមានការអនុញ្ញាតឬក៏អាជ្ញាប័ណ្ណឡើយលើកលែងតែពួកគេមានការអនុញ្ញាតឬក៏អាជ្ញាប័ណ្ណពាក់ព័ន្ធទាំងនោះរួចទៅហើយ ហើយសកម្មភាពការងារគឺត្រូវតែមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងលទ្ធផលសិក្សានៃការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាន។
- ព័ត៌មានអំពីសកម្មភាពដែលតម្រូវឲ្យមានការអនុញ្ញាតឬក៏អាជ្ញាប័ណ្ណ ត្រូវតែមានរួមបញ្ចូលនៅក្នុងកំណត់ត្រាឯកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស (Student Placement Record) ហើយយល់ព្រមដោយភាគីទាំងអស់ (ដោយរួមទាំងមាតា បិតាឬក៏អ្នកថែទាំ) មុននឹងមានការទទួលយកសំណើដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាន។

# ផ្នែក 3

# ការថែគ្រងសិស្សឲ្យមានសុវត្ថិភាព

- គ្រប់ពេលវេលាទាំងអស់ សុវត្ថិភាពនិងកិច្ចការពារសិស្សគឺមានសារសំខាន់បំផុតចំពោះ Department of Education and Training (ក្រសួង)។ តម្រូវការនេះ រួមទាំងនៅគ្រាដែលសិស្សកំពុងចូលរួមកម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋានផងដែរ។
- ការប្រស្រ័យទាក់ទងជាទៀងទាត់និងដោយមានប្រសិទ្ធភាព ជាមួយមាតាបិតា និងអ្នកថែទាំ ព្រមទាំងនិយោជកដែលទទួលយកសិស្ស គឺជាកត្តាសំខាន់ចាំបាច់ សំរាប់កម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋាន។
- ក្រសួងផ្តល់ឲ្យនិយោជកនូវគោលការណ៍ណែនាំពាក់ព័ន្ធការសិក្សារៀនសូត្រ នៅតាមការដ្ឋានសំរាប់និយោជក *(An Employer's Guide to Workplace Learning)* ដើម្បីជួយឲ្យនិយោជកផ្តល់នូវឱកាសប្រកបដោយប្រសិទ្ធិភាព និង សុវត្ថិភាពដល់សិស្ស ក្នុងការសិក្សារៀនសូត្រនៅពេលគេឯកពិសោធន៍ការងារតាមការដ្ឋាន។ *គោលការណ៍ណែនាំសំរាប់និយោជក*ដែលពេញទៅដោយ ព័ត៌មាននេះ រួមបញ្ចូលទាំងឱវាទអំពីយុវជន និងកិច្ចការសុវត្ថិភាព សកម្មភាពដែលគេហាមឃាត់ និងការណែនាំឲ្យសិស្សស្គាល់ការដ្ឋានដែលទទួលសិស្សឲ្យធ្វើការ។

  គោលការណ៍ណែនាំនេះក៏មានផ្ទុកព័ត៌មានសំខាន់ៗអំពីកិច្ចការពារកុមារផងដែរ។ និយោជកត្រូវធានាឲ្យជាក់ច្បាស់ថា បុគ្គលិកទាំងអស់មានការយល់ដឹងអំពីការទទួលខុសត្រូវពិសេសទាំងឡាយពាក់ព័ន្ធនឹងការធ្វើការជាមួយសិស្ស។
- បុគ្គលិករបស់ក្រសួងត្រូវរាយការណ៍ក្តីមន្ទិលសមរម្យទាំងឡាយណាដែលកុមារឬក៏ជនក្មេងវ័យណាម្នាក់អាចប្រឈមមុខនឹងគ្រោះថ្នាក់។ បុគ្គលិកទាំងនោះក៏ត្រូវរាយការណ៍ផងដែរអំពីការចោទប្រកាន់ទាំងឡាយប្រឆាំងនឹងនិយោជកឬក៏និយោជិតរបស់ខ្លួនពាក់ព័ន្ធនឹងកិច្ចការពារកុមារនេះ។
- ឫកពារណាមួយ ដែលមានលក្ខណៈពាក់ព័ន្ធនឹងផ្លូវភេទជាមួយនឹងសិស្សគឺ មិនអាចទទួលយកបានឡើយ ហើយនឹងនាំឲ្យមានការចាត់វិធានការជាបន្ទាន់។ និយោជក ឬក៏បុគ្គលិកក្រសួងត្រូវផ្តល់ដំណឹងទៅនាយកសាលារៀន (Principal) ឬក៏អ្នកគ្រប់គ្រងវិជ្ជាស្ថាន TAFE NSW ដែលទទួលខុសត្រូវនោះ នូវការចោទប្រកាន់ប្រឆាំងនឹងនិយោជិតណាម្នាក់ពាក់ព័ន្ធនឹងកិច្ចការពារកុមារនេះ។ នៅក្នុងបរិបទនេះ និយោជិតក៏រួមបញ្ចូលទាំងនិយោជកផងដែរ។

  ជាការឆ្លើយតបទៅវិញ នាយក ឬក៏អ្នកគ្រប់គ្រងវិជ្ជាស្ថាន TAFE ត្រូវផ្តល់ដំណឹង ទៅអង្គភាពផ្នែកឫកពារចរិយានិងសមត្ថភាពនិយោជិត (Employee Performance and Conduct Unit) របស់ក្រសួង ដែលអាចនឹងចាត់វិធានការថែមទៀត បើសិន ជាគប្បីនឹងធ្វើ។ លើសពីនេះទៅទៀត គេនឹងរាយការណ៍ អំពីការចោទប្រកាន់ធ្ងន់ធ្ងរទៅ Department of Community Services និង/ឬក៏ NSW Police បើសិន ជាសមរម្យនឹងធ្វើ។
- នៅក្នុងគ្រាដែលសិស្សមានផែនការទទួលយកកម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋាន នៅកន្លែងធ្វើការដែលមានការពាក់ព័ន្ធនឹងកុមារ, ឧទាហរណ៍ មានដូចជាសាលារៀន មណ្ឌលថែទាំកុមារឬក៏មន្ទីរពេទ្យជាដើមនោះ ជនយុវវ័យរបស់លោក អ្នកត្រូវបំពេញសេចក្តីប្រកាសអំពីការងារហាមឃាត់ (Prohibited Employment Declaration) មួយជាមុនសិន។ ការធ្វើបែបនេះគឺ ដើម្បីធានាឲ្យមានការរើសយក តែជនសមរម្យសំរាប់ធ្វើការជាមួយកុមារ ហើយក៏ជាតម្រូវការចាំបាច់នៅក្រោមគោលការណ៍ណែនាំរបស់ Commission for Children and Young People ផងដែរ។ សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO នឹងផ្តល់ជូន ក្រដាសធ្វើសេចក្តីប្រកាសនេះទៅសិស្សដែលត្រូវការបំពេញក្រដាសនេះ។

## ចុះពីរឿងពាក់ព័ន្ធនឹងគ្រាអាសន្នវិញ តើយ៉ាងណាដែរ?

នៅក្នុងខណៈដែលគេយកចិត្តទុកដាក់ក្នុងការរៀបចំកម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋាន ហើយការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋានសឹងតែទាំងអស់ដំណើរការដោយគ្មានបញ្ហាអ្វីក៏ដោយ ក៏ជួនកាលហេតុការណ៍ដែលគេមិនបានគិតទុក ជាមុនអាចកើតមានឡើងផងដែរ នៅក្នុងកាលៈទេសៈដ៏កំរ។

ក្រសួងមានបទបញ្ញត្តិមួយចំនួនសំរាប់ជួយសិស្សនៅក្នុងករណីដែលគេជួបប្រទះ នឹងគ្រោះអាសន្ន។ បញ្ញត្តិមួយគឺតម្រូវការដែលសិស្សត្រូវមានមនុស្សសំរាប់គេទាក់ទងនៅគ្រាអាសន្ន សំរាប់ពេលម៉ោងនៃការដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាននិងមួយទៀតគឺសិស្សត្រូវមានប័ណ្ណតូចមួយ (ទំរង់ការសុវត្ថិភាព និងគ្រា អាសន្ន-ប័ណ្ណសិស្សសំរាប់ការទាក់ទង-*[Safety and Emergency Procedures – Student Contact Card]* ) នៅជាប់នឹងខ្លួនគ្រប់ពេលដែលគេធ្វើ

ការដកពិសោធន៍ការងារតាមការដ្ឋាន។ ប័ណ្ណនេះបង្ហាញអំពីអ្នកដែលគេអាចទាក់ទងបាននៅគ្រាមានអាសន្ន។ ប័ណ្ណនេះជាទូទៅមានទំហំប៉ុនប័ណ្ណឥណទានធនាគារ ហើយអាច ប្រើបានដោយលាក់លៀមប្រុងប្រយ័ត្ន។ ប័ណ្ណនេះក៏អាចមានផ្ទុកឱវាទអំពីសុវត្ថិភាពផងដែរ។

- *ទំរង់ការសុវត្ថិភាពនិងគ្រាអាសន្ន-ប័ណ្ណសិស្សសំរាប់ការទាក់ទង* នេះ ផ្តល់ដោយ សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO ។ សិស្សត្រូវបំពេញនិងផ្តល់ព័ត៌មានសំរាប់ការប្រើទាក់ទងនៅគ្រាមានអាសន្ន សំរាប់ការពិនិត្យមើលខុសត្រូវ និងដើម្បីទាញយកព័ត៌មានដែលមានផ្តល់ឲ្យនៅក្នុងកំណត់ត្រាដកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស (Student Placement Record)។ ប័ណ្ណនេះ សំរាប់តែការប្រើប្រាស់របស់សិស្សប៉ុណ្ណោះ- និងសំរាប់គ្រាអាសន្ន។
- នៅក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា បើសិនជាជនយុវវ័យរបស់លោកអ្នក មានការជឿជាក់ជាប្រាកដថាខ្លួនគេប្រឈមមុខនឹងគ្រោះថ្នាក់ ហើយគ្មានទំនុកចិត្តក្នុងការនាំរឿងរ៉ាវនេះប្រាប់និយោជកដែលទទួលសិស្ស ឬក៏អ្នកមើលការខុស ត្រូវនៅការដ្ឋាននោះ សិស្សគប្បីទូរស័ព្ទទៅអ្នកដែលគេជ្រើសតាំងសំរាប់ការទាក់ទងដែលសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO ផ្តល់ឲ្យ ហើយលេខទូរស័ព្ទនោះក៏មានសរសេរនៅលើប័ណ្ណសិស្សសំរាប់ការទាក់ទងផងដែរ ។ បើសិនជាសិស្សមានត្រូវរបួសយ៉ាងដំណំ សិស្សគប្បីទាក់ទងលោកអ្នកផងដែរ។ គេនឹងសរសេរលេខទូរស័ព្ទសំរាប់ទាក់ទង លោកអ្នកនៅលើប័ណ្ណនោះផងដែរ។
- បើសិនជាគ្មានបុគ្គលិកបង្រៀនសមរម្យណាម្នាក់អាចស្ម័គ្រចិត្តធ្វើជាអ្នកដែលគេអាចទាក់ទងនៅក្នុងករណីគ្រាអាសន្ន ដោយរាប់បញ្ចូលទាំងពេលបញ្ចប់ការបង្រៀននៅក្នុងថ្នាក់ រហូតទៅដល់គ្រាបញ្ចប់ម៉ោងធ្វើការធម្មតានោះ ការដាក់សិស្សឲ្យធ្វើការដកពីសោធន៍ការងារតាមការដ្ឋានមិនអាចប្រព្រឹត្តទៅនៅក្នុងអំឡុងពេលនោះបានឡើយ។
- នៅក្នុងករណីមួយចំនួនតូច ជាទូទៅសំរាប់សិស្សថ្នាក់ទី11 និងថ្នាក់ទី 12, ការដាក់ សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាន អាចបន្ត **ក្រៅពេលម៉ោងធ្វើការធម្មតា** បាន។ សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO នឹងបង្ហាញអំពីហេតុការណ៍នេះនៅក្នុងកំណត់ត្រាដកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស។ បើសិនជាសិស្សមានការជឿជាក់ថា ខ្លួនគេអាចប្រឈមមុខនឹងគ្រោះថ្នាក់ នៅក្នុងអំឡុងពេលក្រៅម៉ោងធ្វើការធម្មតានោះ សិស្សត្រូវតែទាក់ទងលោកអ្នក ដែលជា មាតា/បិតា ឬអ្នកថែទាំ សិស្ស។ លោកអ្នកមិនចាំបាច់ធ្វើការស៊ើបអង្កេត ឬក៏ដោះស្រាយបញ្ហាអ្វីឡើយ: គ្រាន់តែដកយកកូនលោកអ្នកចេញពីគ្រោះថ្នាក់ដែលអាចកើតមានឡើងនោះទៅបានហើយ។ សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO ជាអ្នកទទួលខុសត្រូវក្នុងការស្វែងអង្កេតបញ្ហានេះ នៅក្នុងការដ្ឋានឲ្យបានឆាប់ទៅតាមលទ្ធភាព ក្រោយពីលោកអ្នកបានរាយការណ៍រួច។ សាលានឹងជំរាបឲ្យលោកអ្នកបានជ្រាបអំពីលទ្ធផលនោះ។
- ចំពោះរយៈនៅក្រៅម៉ោងធ្វើការធម្មតាតែប៉ុណ្ណោះ លោកអ្នកអាចជ្រើសរើសជនពេញវ័យណាម្នាក់ផ្សេងទៀតដែលចេះទទួលខុសត្រូវ ដែលសិស្សមានការទុកចិត្តឲ្យធ្វើជាអ្នកសំរាប់គេទាក់ទងជំនួសលោកអ្នក។ ត្រូវមានការផ្តល់ព័ត៌មានអំពីជននោះនៅលើកំណត់ត្រាដកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស ដែលជននោះត្រូវតែចុះហត្ថលេខា។ មនុស្សសំរាប់គេទាក់ទងនេះ មិនអាចជានិយោជកដែលទទួលសិស្ស ឬក៏និយោជិតណាម្នាក់របស់និយោជកនោះឡើយ ហើយមិនអាចជាសង្សាររបស់សិស្សនោះដែរ។
- **លោកអ្នក ឬក៏ជនដែលលោកអ្នកជ្រើសតាំងឲ្យធ្វើជាអ្នកសំរាប់គេទាក់ទង** ត្រូវរាយការណ៍អំពីគ្រោះអាសន្នទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងសិស្ស នៅក្នុងអំឡុងពេលនៃការដាក់សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាន ក្រៅម៉ោងធ្វើការធម្មតាទៅសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO របស់ សិស្ស។ កិច្ចការនេះត្រូវធ្វើឲ្យបានឆាប់ទៅតាមលទ្ធភាព ក្រោយពីឧប្បត្តិហេតុនោះបានកើតឡើង, ឧទាហរណ៍ បើមានលទ្ធភាពធ្វើបាន គឺធ្វើនៅថ្ងៃបន្ទាប់នៃឧប្បត្តិហេតុនោះ។ សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO នឹងធ្វើការដោះស្រាយឧប្បត្តិហេតុនោះ ហើយចាត់ឲ្យមានវិធានការសមរម្យទៅតាមការគួរ។
- មុននឹងមានការយល់ព្រមជាចុងក្រោយពីសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO ជាការសំខាន់ដែល លោកអ្នកផ្តល់**លេខ Medicare** និងព័ត៌មានសំរាប់ គេទាក់ទងនៅលើផ្នែកសំរាប់មាតាបិតា/អ្នកថែទាំ ត្រូវបំពេញលើកំណត់ត្រាដក ពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស។ គេត្រូវការលេខ Medicare សំរាប់គ្រា មានជំងឺឈឺថ្កាត់ នៅក្នុងអំឡុងពេលការដាក់សិស្សឲ្យដកពិសោធន៍ការងារតាម ការដ្ឋាន ។ សិស្សដែលគ្មានលេខ Medicare អាចផ្តល់ព័ត៌មានអំពីវេជ្ជបណ្ឌិត របស់ខ្លួន (GP) សំរាប់ឲ្យគេទាក់ទង។ យើងខ្ញុំសូមអរគុណចំពោះការជួយផ្តល់ ព័ត៌មានទាំងនេះ។
- សិស្សគប្បីផ្តល់លេខ Medicare នេះផងដែរនៅលើ *ទំរង់ការសុវត្ថិភាពនិងគ្រាអាសន្ន-ប័ណ្ណសិស្សសំរាប់ការទាក់ទង* របស់ខ្លួន។
- បើសិនជាលោកអ្នកមានសំណួរអ្វីស្តីអំពីការរៀបចំសំរាប់ការដាក់សិស្សឲ្យដកបទពិសោធន៍ការងារតាមការដ្ឋានឲ្យជនយុវវ័យរបស់លោកអ្នក សូមទាក់ទង សាលារៀន ឬវិជ្ជាស្ថាន TAFE NSW ។ សំណួរទាំងនេះ មានរួមបញ្ចូលទាំងសំណូមពរសុំដាក់សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាន ស្នើឡើងដោយសិស្សរៀននៅថ្នាក់ទី 8 ដល់ថ្នាក់ទី 10 ដែលអាចបន្តក្រៅម៉ោងធ្វើការធម្មតា។

## ផ្នែក 4
## បទបញ្ញត្តិស្តីអំពីសំណងនិងការធានារ៉ាប់រង

ក្រសួងមានបទបញ្ញត្តិមួយចំនួនសំរាប់ការពារសិស្សនិងនិយោជកទាំងឡាយ ដោយរួមទាំង :

- ការរៀបចំឲ្យមានការធានារ៉ាប់រងសំរាប់សិស្សដែលត្រូវរបួសនៅគ្រា ការសិក្សា រៀនសូត្រនៅតាមការដ្ឋាន ដោយរួមទាំងការធ្វើដំណើរទៅនិងមកពីការដ្ឋាន។ មាតាបិតា និងអ្នកថែទាំនឹងត្រូវតែដាក់ពាក្យទាមទារសំណងពី Medicare និងមូលនិធិសុខភាពឯកជនជាមុនសិន មុននឹងធ្វើសំណូមពរអ្វីមួយទៅ កាន់ក្រសួងឲ្យបង់សងការចំណាយទាំងឡាយណាដែលនៅមិនទាន់បានទទួលសំណង។
- កិច្ចការពារសំរាប់និយោជក នៅក្នុងព្រឹត្តិការណ៍ដែលមានបណ្តឹងអ្វីមួយប្រឆាំងនឹងនិយោជក ដោយសារការមានរបួសដល់សិស្ស ឬក៏សំណងចំពោះការខូចខាតដល់ទ្រព្យសម្បត្តិ បង្កឡើងដោយសិស្សដែលបិតនៅក្នុងកម្មវិធីការសិក្សារៀន សូត្រនៅតាមការដ្ឋាន។ ប៉ុន្តែកិច្ចការពារនេះមានលក្ខខណ្ឌ។

បើសិនជាសិស្សរងរបួសយ៉ាងដំណំ ដោយសារការចូលរួមនៅក្នុងកម្មវិធីការសិក្សា រៀនសូត្រនៅតាមការដ្ឋានដែលមានការយល់ព្រមនោះក្រសួងត្រូវធ្វេឲ្យប្រាកដ

ថា សិស្សនឹងមិនចាញ់ប្រៀបជនណាម្នាក់ដែលមានការងារធ្វើដោយមានប្រាក់បៀវត្សរ៍ ហើយរងរបួសដូចគ្នានេះដោយមានការធានាគ្រប់គ្រង ពីច្បាប់សំណងជំងឺចិត្តដល់និយោជិត (Workers' Compensation Act) នោះឡើយ។ ដោយសារមូលហេតុនេះ ហើយ ក្រសួងនឹងប្រើច្បាប់ (Workers' Compensation Act) នេះជាបទដ្ឋានមួយ សំរាប់សងជំងឺចិត្តសិស្ស ចំពោះការចំណាយលើការព្យាបាល និងនីតិសម្បទា។
ដោយសារសិស្សមិនបានទទួលប្រាក់បៀវត្សរ៍ សំណងជំងឺចិត្តនេះ មិនរួមបញ្ចូល ការបាត់បង់ប្រាក់ចំណូលឡើយ។ ដូចគ្នាទៅនឹងនិយោជិតដែលមានប្រាក់បៀវត្សរ៍ដែរ សិស្សក៏មានសិទ្ធិផងដែរ នៅក្រោមច្បាប់រដ្ឋប្បវេណី ក្នុងការស្វែងទាមទារសំណងជំងឺចិត្ត បើសិនជាគេអាចបង្ហាញថា របួសនោះបានបង្កឡើង ដោយការធ្វេសប្រហែសរបស់និយោជកដែលទទួលសិស្ស, ក្រសួងឬក៏ភាគីទីបីណាមួយ។

បទបញ្ញត្តិធានារ៉ាប់រងទាំងនេះ អនុវត្តតែចំពោះកម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋាន ដែលយល់ព្រមដោយសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬ P/C RTO សំរាប់តែការដាក់សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាននៅខាងក្រៅតែប៉ុណ្ណោះ។ ការយល់ព្រមនេះមានកត់ត្រានៅក្នុងកំណត់ត្រាដកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស (Student Placement Record)។

P/C RTO នឹងផ្តល់សេចក្តីពិស្តារអំពីការរៀបចំការធានាសំរាប់ការដាក់សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាន នៅក្នុងរង្វង់អង្គការរបស់ខ្លួន។ យ៉ាងណាមិញ សាលារៀនរបស់កូនលោកអ្នក នៅតែមានភារកិច្ចនៃការថែគ្រង នៅក្នុងគ្រាដែលកូនលោកអ្នកចូលរួមនៅក្នុងវគ្គសិក្សាដែល រៀបចំឡើង ដោយ RTO (P/C RTO) ឯកជន ឬក៏សហគមន៍ ដែលគេជួលឲ្យផ្តល់វគ្គសិក្សាដល់សិស្ស។ សាលាធ្វើការទាក់ទងជាទៀងទាត់ជាមួយ RTO (P/C RTO) ដែលរៀបចំកម្មវិធីដាក់សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាន សំរាប់សិស្សសាលារបស់ខ្លួន។

## ផ្នែក 5
## វិធីដ៏ប្រសើរដើម្បីជួយកូនលោកអ្នក

**មុននឹងមានការរៀបចំដាក់សិស្សឲ្យដកពិសោធន៍ការងារតាមការដ្ឋាន** សូមអានព័ត៌មានអំពីការសិក្សារៀនសូត្រ អំពីការដ្ឋានដែលផ្តល់ជូនដោយអ្នករៀបចំ ហើយចូលរួមកិច្ចប្រជុំពាក់ព័ន្ធទាំងឡាយ។ បើសិនជាលោកអ្នកមិនច្បាស់ប្រាកដ អំពីរឿងអ្វីមួយនោះ សូមស្នើសុំឲ្យគេពន្យល់បន្ថែម។

**ជំរុញលើកទឹកចិត្តឲ្យកូនលោកអ្នក:**

- ពិភាក្សាអំពីការបង្កើតឲ្យមាននូវចំណាប់អារម្មណ៍មុខអាជីពរបស់ខ្លួន និងជំរើសការងារ
- ស្រាវជ្រាវឧស្សាហកម្មដែលគេចង់បាននិងអាជីពពាក់ព័ន្ធទាំងឡាយ ឧទាហរណ៍ មានដូចជា ការប្រើប្រាស់សេវាកម្មជាតិអូស្ត្រាលីសំរាប់ការផ្តល់ព័ត៌មានផ្នែកមុខអាជីព: **www.myfuture.edu.au**
- សូមបំពេញទំព័រ Workplace Learning Research ទាំងពីរនៅក្នុងសៀវភៅកំណត់ ហេតុជំនាញការពាក់ព័ន្ធនឹងការងារ *(Employment Related Skills Logbook)* របស់សិស្ស
- ពិភាក្សានូវអ្វីដែលគេគ្រោងសិក្សាពីការដកបទពិសោធន៍ការងារតាមការដ្ឋាន និងសំណួរដែលសិស្សប្រហែលជានឹងសាកសួរអ្នកមើលការខុសត្រូវរបស់សិស្ស ឬក៏និយោជកដែលទទួលយកសិស្ស
- ស្វែងយល់នូវអ្វីដែលសិស្សត្រូវធ្វើ ដើម្បីត្រៀមលក្ខណ:សំរាប់ការដកពិសោធន៍ការងារតាមការដ្ឋាន។ ឧទាហរណ៍ បំពេញសកម្មភាពដែលរៀបចំដោយសាលារៀន ឬ វិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO មុនពេលទៅដកបទពិសោធន៍ការងារតាមការដ្ឋាន។

**ក្នុងនាមជាមាតាបិតាឬអ្នកថែទាំ លោកអ្នកក៏អាចជួយផងដែរដោយ:**

- ផ្តល់ដំណឹងទៅសាលារៀនអំពីកន្លែងដកបទពិសោធន៍ការងារតាមការដ្ឋានសមរម្យណាដែលលោកអ្នកដឹង ឬក៏អាចផ្តល់ជូន
- ផ្តល់ដំណឹងទៅសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO អំពីពិការភាព បញ្ហាសុខភាព ការប្រើថ្នាំពេទ្យ ប្រតិកម្ម ឬក៏ការដាក់កំហិតទាំងឡាយណាដែល ធ្វើឲ្យប៉ះពាល់ដល់សិស្ស ដែលយើងខ្ញុំគប្បីគិតគូរ ជាពិសេស បើសិនជាបញ្ហានេះអាចធ្វើឲ្យប៉ះពាល់ដល់សុវត្ថិភាព និងការមើលការខុសត្រូវលើសិស្ស នៅពេលដកបទពិសោធន៍ការងារតាមការដ្ឋាន។

  នៅលើកំណត់ត្រាដកពិសោធន៍ការងារតាមការដ្ឋានរបស់សិស្ស មានកន្លែងសំរាប់ឲ្យលោកអ្នកផ្តល់ព័ត៌មានទាំងនេះ បើពុំនោះសោតទេ លោកអ្នកអាចភ្ជាប់ព័ត៌មាននេះ ទៅនឹងកំណត់ត្រានោះបាន។ **បើសិនជាកូនលោកអ្នកត្រូវការការកែតម្រូវនៅការិយាល័យកន្លែងដកពិសោធន៍ការងារតាមការដ្ឋាន ដើម្បីបំពេញតាមសេចក្តីត្រូវការពិសេសរបស់កូនលោកអ្នកនោះ សូមទាក់ទងសាលារៀន ឬក៏វិជ្ជាស្ថាន TAFE NSW ។**

**នៅពេលមានការបញ្ជាក់អំពីការងារណាមួយនោះ សូមជួយកូនរបស់លោកអ្នក ដើម្បីស្វែងយល់អំពី :**

- រៀបចំសកម្មភាពដទៃទៀតឡើងវិញ ដើម្បីផ្តល់អាទិភាពដល់ការសិក្សារៀនសូត្រអំពីការដ្ឋាន
- សំលៀកបំពាក់ និងតម្រូវការផ្សេងៗទៀត សំរាប់ទៅធ្វើការដកបទពិសោធន៍ការងារតាមការដ្ឋាន មានដូចជាស្បែកជើងឃ្លុបជាដើម។
- ម៉ោងចាប់ផ្តើមនិងម៉ោងបញ្ចប់ (មានការរំពឹងទុកថា សិស្សត្រូវធ្វើការក្នុងរង្វង់ម៉ោងធ្វើការធម្មតា ក៏ប៉ុន្តែមិនត្រូវចូលធ្វើការមុនម៉ោង ៧ ព្រឹក ឬក្រោយម៉ោង៦ យប់ឡើយ បើសិនជាកូនលោកអ្នកមានអាយុក្រោម 15ឆ្នាំ)
- អ្វីដែលសិស្សត្រូវដឹងសំរាប់ថ្ងៃចាប់ផ្តើមដំបូង (ការរៀបចំដំណើរ ម៉ោងទៅដល់ មនុស្សដែលគេត្រូវទាក់ទង)
- អាហារដ្ឋានឬក៏កន្លែងទទួលទានអាហារអ្វីខ្លះដែលមាននៅការដ្ឋាន ឬក៏សិស្សត្រូវយកចំណីអាហារទៅជាមួយ។

**នៅក្នុងអំឡុងពេលសិស្សដកពិសោធន៍ការងារតាមការដ្ឋាន សូមលើកទឹកចិត្តឲ្យកូនលោកអ្នក:**

- បំពេញកិច្ចការទាំងឡាយឬសៀវភៅកិច្ចការសិក្សា

- និយាយជាមួយមនុស្សដែលគេជ្រើសតាំងសំរាប់ឲ្យទាក់ទងជាបន្ទាន់ បើសិនជាមានការលំបាកអ្វីមួយ, ឧទាហរណ៍ បញ្ហាសុវត្ថិភាព គ្រោះថ្នាក់ របួស ជម្លោះការងារ ការរំខានឃាយី ឬក៏ការសម្លុតធ្វើបាបជាដើម។

**លើកទឹកចិត្តឲ្យកូនធ្វើការពិភាក្សាជាមួយលោកអ្នកៈ**

- អំពីរបៀបដែលអង្គការទទួលសិស្សឲ្យរៀនធ្វើការ ធ្វើកិច្ចការរបស់ខ្លួន ដោយគិតអំពីទស្សនៈរបស់អង្គការនោះ
- តើការងារនោះមានតម្រូវការហ្វឹកហ្វឺន និងការអប់រំអ្វីខ្លះ
- តើស្ថានភាពធ្វើការមានលក្ខណៈយ៉ាងណា និងតួនាទីសហជីព
- បញ្ហាសុវត្ថិភាពនិងសុខភាពផ្នែកការងារ (occupational health and safety [OH&S]) នៅក្នុងការដ្ឋាន
- តើនិយោជិតមានការទទួលខុសត្រូវនិងសិទ្ធិអ្វីខ្លះនៅការដ្ឋាន
- អ្វីៗដែលកូនលោកអ្នកនឹងសិក្សារៀនសូត្របានពីចំណុចល្អ គុណសម្បត្តិ និងចំណង់ចំណូលចិត្តរបស់ខ្លួន នៅក្នុងវិស័យការងារនេះ នៅពេលអនាគត។

**ក្រោយពីការបំពេញកិច្ចការជកពិសោធន៍ការខារតាមការដ្ឋានរួចហើយនោះ សូមពិភាក្សាដោយផ្ទាល់ជាមួយកូនលោកអ្នកភ្លាមអំពីៈ**

- ពិភាក្សាអំពីរបាយការណ៍របស់និយោជកជាមួយលោកអ្នក និងជាមួយគ្រូទាំងឡាយដែលមានការពាក់ព័ន្ធ
- បំពេញសេចក្តីនៅក្នុង*សៀវភៅកំណត់ហេតុជំនាញការពាក់ព័ន្ធនឹងការងារ (Employment Related Skills Logbook)* របស់ខ្លួន
- ពិនិត្យឡើងវិញនូវផែនការអាជីពនៃជនយុវវ័យរបស់លោកអ្នក ព្រមទាំងការងារ ការរៀនសូត្រ ការហ្វឹកហ្វឺន និងជំរើសមុខអាជីព ទៅពេលអនាគត
- ស្ថាបនានិងរក្សាបណ្តាញទំនាក់ទំនងចាប់ពីចំណុចនេះទៅ និងកន្លែងឯកពិសោធន៍ការងារតាមការដ្ឋានឯទៃទៀត ដើម្បីសុំឱវាទ ជំនួយ និងស្វែងរកឱកាសនាពេលអនាគត។ គួរមានការរក្សាព័ត៌មានទាំងនេះទុកសំរាប់ការ ប្រើប្រាស់ទៅថ្ងៃមុខ។

## ផ្នែក 6
## ទំនាក់ទំនងសំខាន់ៗ

សូមអរគុណចំពោះការចំណាយពេលអានព័ត៌មានដ៏សំខាន់នៅក្នុង *គោលការណ៍ណែនាំ* នេះ។ យើងខ្ញុំសង្ឃឹមថា លោកអ្នកមានទំនុកចិត្ត ហើយត្រៀមលក្ខណៈបានយ៉ាងគាប់ប្រសើរសំរាប់ជួយជនយុវវ័យរបស់លោកអ្នក នៅគ្រាដែលគេចាប់យកឱកាសសិក្សារៀនសូត្រអំពីការដ្ឋានដ៏ថ្លៃថ្លាផ្តល់ដោយសាលារៀន ឬ វិជ្ជាស្ថាន TAFE NSW ។

បើសិនជាលោកអ្នកមានសំណួរអ្វី សូមទាក់ទងជាមួយនឹងបុគ្គលិកណាម្នាក់ ដែលមានផ្តល់ជូននៅខាងក្រោមនេះ

- អ្នកសំរបសំរួលកម្មវិធីសិក្សារៀនសូត្រនៅតាមការដ្ឋាន (workplace learning program coordinator) នៅតាមសាលារៀន ឬវិជ្ជាស្ថាន TAFE NSW ឬក៏ P/C RTO របស់លោកអ្នក។ បុគ្គលិកនេះអាចជាអ្នកផ្តល់ឱវាទមុខអាជីព, អ្នកសំរបសំរួល VET ឬអ្នកសំរបសំរួលសាលានិងការងារ (School to Work coordinator)
- ទីប្រឹក្សាផ្នែកអប់រំវិជ្ជាជីវៈនៅតាមការិយាល័យតំបន់ដែលមានការពាក់ព័ន្ធរបស់ NSW Department of Education and Training
- ទីប្រឹក្សានៅវិជ្ជាស្ថាន TAFE NSW - TVET នៅតាមវិជ្ជាស្ថាន TAFE NSW ដែលមានការពាក់ព័ន្ធ
- អ្នកសំរបសំរួលជាន់ខ្ពស់ផ្នែកការសិក្សារៀនសូត្រនៅតាមការដ្ឋាន (Senior Coordinator Workplace Learning), Vocational Education in Schools Directorate តាមទូរស័ព្ទលេខ 02 9244 5071 ។

**និយោជករបស់សិស្សៈ**

(សំរាប់បំពេញនៅគ្រាដាក់សិស្សឲ្យឯកពិសោធន៍ការងារតាមការដ្ឋាន)

| | |
|---|---|
| Host business: | |
| Contact person: | |
| Telephone: | |
| Mobile: | |
| Address: | |

© NSW Department of Education and Training (Vocational Education in Schools Directorate) November 2005

Al rights reserved. Except under conditions described in the Copyright Act 1968 and subsequent amendments, no part of this publication may be reproduced by any process without permission in writing from the publisher.

This document may be photocopied to support students from NSW government schools or students enrolled in TAFE NSW institutes.

ISBN 0731384458  SCIS 1241375

POINT5590